នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Mar-2020, 10:11
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ/Public

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រកំណត់សម្រាប់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Chandra N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence N. MWACHANDE-MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
លោក ពេជ អង្គ
លោកស្រី Megan HIRST

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បន្ថែមចំនួនទំព័រកំណត់សម្រាប់ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០២[1]។ បណ្តឹងសាទុក្ខនេះមានឧបសម្ព័ន្ធ ក ដែលមាន (i) ចំនួន ៧៦ ទំព័រ ដែលជាផ្នែកដ៏សំខាន់បំផុតចំពោះសារណារបស់ ខៀវ សំផន[2] និង (ii) សារណាដែលមានចំនួន ៧៥០ទំព័រ ដែលបង្រួមសេចក្តីយោងនៃសេចក្តីសន្និដ្ឋានផ្សេងទៀតនៅក្នុងសំណុំរឿង០០២[3]។

២. អាស្រ័យមូលហេតុដូចជំរាបជូនខាងក្រោម សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការទទួលយកបណ្តឹងសាទុក្ខនេះទេ។ ទោះជាយ៉ាងណា ដើម្បីធានាដល់ភាពត្រឹមត្រូវ និងលទ្ធភាពក្នុងការឆ្លើយតបឲ្យបានគ្រប់គ្រាន់ទៅនឹងការចោទប្រកាន់នៅក្នុងបណ្តឹងសាទុក្ខដ៏វែងរបស់ ខៀវ សំផន សហព្រះរាជអាជ្ញាសូមស្នើដល់ អ.ជ.ត.ក ឲ្យផ្តល់ដល់យើងខ្ញុំចំនួន ១៤៥ ទំព័របន្ថែមសម្រាប់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

## II. ប្រវត្តិនីតិវិធី

៣. សាលក្រមសំណុំរឿង ០០២/០២ ត្រូវបានចេញក្នុងទម្រង់ជាសេចក្តីសង្ខេប នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[4]។ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់សាលក្រមពេញលេញរបស់ខ្លួន[5]។

៤. នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់[6] ដោយបានកំណត់អត្តសញ្ញាណទម្លើករណ៍សម្រាប់បណ្តឹងសាទុក្ខយ៉ាងហោចណាស់ ១៨២៤ និងសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបានចំនួន ៣៥៥[7]។

---

[1] ឯកសារ **E465** សាលាក្រមសំណុំរឿង ០០២/០២, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ("សាលាក្រមសំណុំរឿង ០០២/០២")។

[2] ឯកសារ **F54.1.1** Annex A – Résumé des Motifs d'Appel de Khieu Samphân (002/02), ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ("ឧបសម្ព័ន្ធ ក នៃសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី")។

[3] ឯកសារ **F54** Mémoire d'Appel de Khieu Samphân (002/02), ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី")។

[4] សេចក្តីសង្ខេបនៃសាលក្រមសំណុំរឿង ០០២/០២, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ *សូមមើលផងដែរ* ឯកសារ **E1/529.1** សេចក្តីប្រកាសសាលក្រម នៃសំណុំរឿង ០០២/០២, ប្រតិចារឹក - ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១៨។

[5] ឯកសារ **E465** សាលក្រមនៃសំណុំរឿង ០០២/០២។

[6] ឯកសារ **E465/4/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២), ចុះថ្ងៃទី១ កក្កដា ឆ្នាំ២០១៩។

[7] ឯកសារ **F45** សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខ, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ("សំណើសុំបន្ថែមពេលវេលានិងបង្កើនចំនួនទំព័ររបស់មេធាវីការពារក្តី"),កថាខណ្ឌ៩។

៥. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ខៀវ សំផន បានសុំពេលវេលារហូតដល់ ១០.៥ ខែ និង ចំនួនទំព័ររហូតដល់ ៩៥០ទំព័រ សម្រាប់សារណាបណ្ដឹងសាទុក្ខរបស់គាត់[8]។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើសុំនេះដោយសំអាងថា ការបន្ថែមពន្យារពេល និងចំនួនទំព័រកំណត់ដែលបានស្នើសុំនេះ មិនធ្លាប់មានពីមុនមកទេ ហើយក៏មិនអាចអនុញ្ញាតដែរ[9]។

៦. នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ អ.ជ.ត.ក បានបង្គាប់ឲ្យ ខៀវ សំផន ដាក់សារណាមិនឲ្យលើសពីចំនួន ៧៥០ ទំព័រ និងបង្គាប់ឲ្យសហព្រះរាជអាជ្ញា ដាក់ចម្លើយតបរបស់ខ្លួនមិនឲ្យលើសពី ៣៥០ ទំព័រ[10]។

៧. នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ខៀវ សំផន បានដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន[11]។

## III. សេចក្ដីសន្និដ្ឋាន

៨. បន្ថែមពីលើសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ដែលបានប្រើប្រាស់ជាអតិបរមាចំនួន ៧៥០ ទំព័រ ដែលបានផ្ដល់ជូនឲ្យគាត់ដោយ អ.ជ.ត.ក នោះ សារណានេះក៏បានយោងឧបសម្ព័ន្ធមួយដែលមានចំនួន ៧៦ ទំព័រ[12] ផងដែរ ដែលមានចំណងជើងថា "ឧបសម្ព័ន្ធ ក - សេចក្ដីសង្ខេបនៃទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) (ដោយមានការកំណត់អត្តសញ្ញាណកំហុសនៅក្នុងកំណត់ហេតុបណ្ដឹងសាទុក្ខ)"[13]។ ដូច ខៀវ សំផន កត់សំគាល់ដែរថាបណ្ដឹងសាទុក្ខរបស់គាត់ មិនបានរៀបចំតាមរបៀបដូចគ្នាទៅនឹងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់គាត់ទេ ហើយគាត់ស្វែងរកការកែតម្រូវភាពខុសគ្នានេះនៅក្នុងឧបសម្ព័ន្ធ ក[14]។ ឧបសម្ព័ន្ធនេះ កំណត់អត្តសញ្ញាណយ៉ាងចំៗអំពី (i) ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខដោយបានយោងទៅដល់ទឡ្ហីករណ៍ដែលមានចេតនា ដែលបានរៀបរាប់នៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់គាត់; (ii) ផ្នែក/ចំណុចនៃសាលក្រមដែលកំពុងតែប្ដឹង; (iii) កំហុសដែលបានចោទប្រកាន់; (iv) សិទ្ធិដែលបានចោទថាត្រូវបានរំលោភ និង (v) វិបាកដែលបានចោទប្រកាន់ដែលកើតចេញពីកំហុស ឬការរំលោភទាំងនោះ។ ដូច្នេះ ឧបសម្ព័ន្ធ ក គឺជាចំណុចស្នូលនៃសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ

---

[8] ឯកសារ **F45** សំណើសុំបន្ថែមពេលវេលានិងបង្កើនចំនួនទំព័ររបស់មេធាវីការពារក្ដី"), កថាខណ្ឌ ១៩។

[9] ឯកសារ **F45/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និង ចំនួនទំព័រកំណត់ សម្រាប់សារណាបណ្ដឹងសាទុក្ខ, ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩។

[10] ឯកសារ **F49** សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ, ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩, កថាខណ្ឌ ៣៦ (ផ្នែកសម្រេចសេចក្ដី)។

[11] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី។

[12] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី, កំណត់សម្គាល់ជើងទំព័រលេខ ៣០។

[13] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក នៃសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី FR 01638787 (ការបកប្រែក្រៅផ្លូវការ)។

[14] ឯកសារ **F54** សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី កំណត់សម្គាល់ជើងទំព័រលេខ ១៧, ៣០។

សំផន ដែលផ្តល់នូវទឡ្ហីករណ៍ជាក់ស្តែងនៃបណ្តឹងសាទុក្ខដែលអំណះអំណាងនៅក្នុងសារណាបណ្តឹងសាទុក្ខនេះបានគាំទ្រ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថាឧបសម្ព័ន្ធនេះ គឺចាំបាច់ចំពោះ អ.ជ.ត.ក និងភាគីជំទាស់ដើម្បីកំណត់អត្តសញ្ញាណលើទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ ខៀវ សំផន និង យល់ថាតើអំណះអំណាងដែលបានធ្វើនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់បានគាំទ្រដល់ពួកវា ឬយ៉ាងណា រួមទាំងថាតើការបញ្ជាក់ច្បាស់លាស់អំពី ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់គាត់ បំពេញនូវបទដ្ឋាននៃការត្រួតពិនិត្យបណ្តឹងសាទុក្ខ ដែរឬអត់។

៩. បន្ថែមលើនេះ ខៀវ សំផន បញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ នៅក្រោមចំណងជើងថា "ការបង្ហាញសារណា"[15] ដើម្បីចៀសវាងការច្រំដែល គាត់បានដាក់បញ្ចូលដោយសេចក្តីយោងនៅខាងមុខអំណះអំណាង ដូចនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់នៅក្នុងសំណុំរឿង០០២/០១ និងសារណាបិទកិច្ចពិភាក្សាដេញដោល នៅក្នុងសំណុំរឿង០០២/០២ ដូច្នោះដែរ[16]។ ការពិនិត្យឡើងវិញនៃសារណាបណ្តឹងសាទុក្ខរបស់គាត់ បង្ហាញថាគាត់បានប្រើជាអប្បបរមានូវចំនួន ២៣៦ទំព័រ នៃឯកសារដែលបានដាក់ពីមុន[17]។

១០. ដូច្នេះ បណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០២ ឡើងដល់ ៧៥០ទំព័រ នៅក្នុងសារណារបស់គាត់ ចំនួន ៧៦ទំព័រ នៅក្នុងឧបសម្ព័ន្ធ ក និងយ៉ាងហោចណាស់ ២៣៦ទំព័រ ដែលគាត់បានដាក់ជាសេចក្តីយោង ដែលជាសរុបមានចំនួនប្រមាណជា ១,០៦២ ទំព័រ ដែលសហព្រះរាជអាជ្ញាត្រូវឆ្លើយតប។ នេះគឺជាចំនួនអប្បបរមានៃចំនួន ៣១២ ទំព័របន្ថែម លើសពីទំព័រដែល អ.ជ.ត.ក គ្រោងទុក ពេលដែលខ្លួនបានបង្គាប់ឲ្យ សហព្រះរាជអាជ្ញាឆ្លើយតប នៅក្នុងកម្រិត ៣៥០ទំព័រ ទៅនឹងសារណាបណ្តឹងសារទុក្ខដែលនឹង មិនលើសពី ៧៥០ទំព័រ។

១១. សហព្រះរាជអាជ្ញាស្នើសុំ ១៤៥ទំព័រ ទៀត ដើម្បីឆ្លើយតបឲ្យមានប្រសិទ្ធិភាពទៅនឹងមូលហេតុដែលមាននៅក្នុងទំព័របន្ថែមទាំងនេះ។ សំណើសុំនេះ (i) គឺសមាមាត្រទៅនឹងចំនួនទំព័រសរុប ដែលត្រូវបានផ្តល់ឲ្យសហព្រះរាជអាជ្ញា ដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ មិនឲ្យលើសពី ៧៥០ ទំព័រ; (ii) គឺចាំបាច់ដើម្បីធានាពីភាពត្រឹមត្រូវក្នុងការប្រព្រឹត្តិចំពោះភាគីនានា ទៅនឹងបណ្តឹងសាទុក្ខ និង (iii) ធានាថា សហព្រះរាជអាជ្ញា គឺអាចមានលទ្ធភាពឆ្លើយតបដោយប្រសិទ្ធិភាព និងគ្រប់ជ្រុងជ្រោយ ទៅនឹងការចោទប្រកាន់របស់ ខៀវ សំផន ដោយហេតុយ៉ាង

---

[15] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី FR 01638005 (ការបកប្រែក្រៅផ្លូវការ)។

[16] ឯកសារ **F54** សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី កថាខណ្ឌ ១៨ *ដោយការលើកឡើងពី* ឯកសារ F17 សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤។ ឯកសារ **E457/6/4/1** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) ចុះថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៧ ត្រូវបានកែប្រែ នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧។

[17] *សូមមើល ឧទា.* ឯកសារ **F54** សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី កំណត់សម្គាល់ជើងទំព័រលេខ ៥២, ១៤០-១៤១, ១៧៨, ២០៣, ២០៨, ២៤៣, ២៨០, ៣០១, ៣០៦, ៦៦៩, ៦៨១-៦៨២, ៦៨៧, ៦៩០, ៨១៦, ៩៩៣, ១០៦១, ១២៣៥, ២១៦៦, ២៣១៦, ៣១៣៩, ៣២២៥, ៣៣០០, ៣៣៧២, ៣៣៨១, ៤០៨៩។

ដូច្នេះហើយ ក៏នឹងជួយដល់ អ.ជ.ត.ក នៅក្នុងការដោះស្រាយពីកំហុសឆ្គងដែលបានចោទប្រកាន់ នៅក្នុងសាលក្រមសំណុំរឿង០០២/០២។

## IV. ឧបាស្រ័យដែលស្នើឡើង

១២. ចំពោះហេតុផលខាងលើនេះ សហព្រះរាជអាជ្ញា ស្នើសុំឲ្យ អ.ជ.ត.ក អនុញ្ញាតផ្តល់ឲ្យខ្លួននូវចំនួន ១៤៥ ទំព័រ បន្ថែមលើសពីកម្រិតបច្ចុប្បន្ន ដែលមានចំនួនកំណត់ ៣៥០ ទំព័រ សម្រាប់ចម្លើយតប របស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលនាំឲ្យចំនួនទំព័រសរុបសម្រាប់ចម្លើយតប របស់ពួកគាត់ គឺមិនលើសពី ៤៩៥ ទំព័រ នោះទេ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |
| | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | |